**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៦.អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅ

# របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន**គ.ជ.យ.**។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.យ.** មានតួនាទីជាសេនាធិការជូន**គ.ជ.យ.** និងមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់**គ.ជ.យ.**
- រៀបចំនិងប្រមូលផ្តុំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់**គ.ជ.យ.**
- រៀបចំនិងបង្កើតកម្មវិធីនិងសេវានានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- សម្របសម្រួលលើកកម្ពស់អន្តរកម្មនិងការងារជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័នឯកជន អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធ
- រៀបចំការប្រជុំ សន្និសីទ ការបណ្តុះបណ្តាល សិក្ខាសាលា និងការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- ផ្តល់ព័ត៌មានថ្មីៗចុងក្រោយទាន់សភាពការណ៍អំពីយុទ្ធសាស្ត្រសំខាន់ៗដើម្បីអភិវឌ្ឍយុវជន
- ជំរុញនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- សិក្សាស្រាវជ្រាវ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- លើកសំណើពិនិត្យនិងកែលម្អគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាជូន**គ.ជ.យ**
- ធ្វើរបាយការណ៍ជូន**គ.ជ.យ.**និងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល**គ.ជ.យ.**ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.យ.** ដឹកនាំដោយអគ្គលេខាធិការមួយរូបនិងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.យ.**មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកអនុវត្តគោលនយោបាយ
- ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

អគ្គលេខាធិការដ្ឋាន**គ.ជ.យ.** អាចពង្រីករចនាសម្ព័ន្ធថែមទៀតតាមការចាំបាច់។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន**គ.ជ.យ.**ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាននិងមានអនុប្រធានផ្នែកមួយចំនួនដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

ផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន**គ.ជ.យ.**អាចមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.យ.**។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន**គ.ជ.យ.** មានមន្ត្រីបម្រើការមកពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន**គ.ជ.យ.** អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៧.-**

ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន**គ.ជ.យ.**
- ផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងគ្រប់គ្រងឯកសាររដ្ឋបាល ចលនវត្ថុ អចលនវត្ថុ និងបញ្ជីសារពើភណ្ឌ

- រៀបចំកសាងផែនការនិងគ្រប់គ្រងហិរញ្ញវត្ថុ
- គ្រប់គ្រងស្ថិតិព័ត៌មាននិងតួលេខរបស់អង្គការស្ថាប័នដែលពាក់ព័ន្ធនឹងការងារអភិវឌ្ឍយុវជន
- ធ្វើទំនាក់ទំនងនិងសហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន
- ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញនិងវិសាមញ្ញរបស់**គ.ជ.យ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផល សកម្មភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.យ.** ប្រគល់ជូន។

**មាត្រា ៨.-**

**ផ្នែកអនុវត្តគោលនយោបាយមានតួនាទីនិងភារកិច្ចដូចតទៅ៖**

- សម្របសម្រួលការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការផ្សេងៗ
- ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានា
- ជំរុញនិងលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពយុវជនប្រកបដោយគំនិតច្នៃប្រឌិត
- សម្របសម្រួលនិងអនុវត្តការបណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ
- សហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងឯកជនពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- បង្កើនកិច្ចសហការដើម្បីផ្តល់ឱកាសឱ្យយុវជនធ្វើជំនួញខ្នាតតូច មធ្យម និងខ្នាតធំ និងផ្តល់ឥណទានក្នុងការចាប់ផ្តើមនិងពង្រីកមុខជំនួញ
- បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាពដល់យុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ យុត្តិធម៌ និងទប់ស្កាត់អំពើហិង្សាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់ការសម្រាក ការកម្សាន្តនិងកីឡា ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច
- សម្របសម្រួលទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្តារយុវនីតិសម្បទាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារយុត្តិធម៌និងដោះស្រាយបញ្ហាយុវជន។

- បង្កើនការចូលរួមរបស់យុវជនក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន សហគមន៍ និងការអភិវឌ្ឍប្រទេសជាតិ
- លើកទឹកចិត្តឱ្យយុវជនចូលរួមបំពេញការងារស្ម័គ្រចិត្តនិងលើកកម្ពស់សាមគ្គីភាព និងសមភាពយេនឌ័រ
- សហការជាមួយគ្រប់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយអំពីការអភិវឌ្ឍយុវជន ជាពិសេសការយល់ដឹងអំពីបរិស្ថាន កសិកម្ម និងទេសចរណ៍
- លើកកម្ពស់សិល្បៈ វប្បធម៌ និងការបណ្តុះបណ្តាលយុវអ្នកនិពន្ធ យុវសិល្បករដែលប្រកបដោយគំនិតច្នៃប្រឌិត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.ឃ.**ប្រគល់ជូន។

**មាត្រា ៩.-**

**ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានតួនាទីនិងភារកិច្ចដូចតទៅ៖**

- រៀបចំផែនការសកម្មភាព និងកំណត់សូចនាករ ដើម្បីត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្តនិងការអភិវឌ្ឍគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- គ្រប់គ្រងទិន្នន័យយុវជននិងវិភាគលទ្ធផលការងារ ដើម្បីកែលម្អការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- សិក្សាស្រាវជ្រាវទៅលើបញ្ហាយុវជននៅក្នុងសង្គមដែលជាមូលដ្ឋានជាក់ស្តែងសម្រាប់អភិវឌ្ឍគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.ឃ.**ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន
នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## អង្គការលេខនៃអគ្គលេខាធិការដ្ឋាន ក.ជ.យ.

